# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ**

លេខ ៦៥២៤ កសក

រាជធានីភ្នំពេញ, ថ្ងៃទី២៥ ខែកក្កដា ឆ្នាំ ២០១៧

### សូមជម្រាបជូន

- ឯកឧត្តម លោក លោកស្រី ប្រធានគ្រប់អង្គភាពក្រោមឱវាទក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- លោកប្រធានមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានី-ខេត្ត

**កម្មវត្ថុ ៖** សំណើយកចិត្តទុកដាក់អនុវត្តតាមការណែនាំលើការរៀបចំលិខិតតាមទម្រង់ណែនាំរបស់ក្រសួង។

**យោង ៖** លិខិតលេខ៤៩១ កសក ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០១៧ របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមជម្រាប ឯកឧត្តម លោក លោកស្រី ជ្រាបថា ដើម្បីឱ្យមានការឯកភាពគ្នាលើទម្រង់លិខិតរដ្ឋបាលរបស់ក្រសួងនោះ ក្រសួងបានធ្វើការណែនាំតាមទម្រង់ដែលបានជូនភ្ជាប់តាមលិខិតលេខ៤៩១ កសក ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០១៧ រួចហើយ។ ក្នុងនោះគំរូលិខិតចំនួន ០៩ ដែលណែនាំឱ្យតាក់តែងដោយប្រើប្រាស់ហ្វុងអក្សរ Khmer OS Battambang គម្រឹមគែមខាងឆ្វេង (Left) ទុក ២,៥ស.ម និងខាងស្តាំ (Right) ទុក ១,៥ស.ម ។

អាស្រ័យហេតុនេះ សូម ឯកឧត្តម លោក លោកស្រី យកចិត្តទុកដាក់អនុវត្តតាមការណែនាំឱ្យបានឯកភាពគ្នាលើទម្រង់លិខិត (សូមជូនភ្ជាប់មកនូវគំរូសាជាថ្មី) តាមការគួរ។

សូម ឯកឧត្តម លោក លោកស្រី ទទួលនូវការរាប់អានដ៏ស្មោះពីខ្ញុំ។

**ត.ប រដ្ឋមន្ត្រី**
**ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**
**អគ្គលេខាធិការ**

ឡោ រស្មី

**ចម្លងជូន៖**
- ថ្នាក់ដឹកនាំក្រសួង
- ខុទ្ទកាល័យរដ្ឋមន្ត្រី
  "ដើម្បីជូនជ្រាប"
- ឯកសារ កាលប្បវត្តិ

អាសយដ្ឋានលេខ ២០០ មហាវិថីព្រះនរោត្តម សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ កម្ពុជា
N° 200 Preah Norodom Blvd., Sangkat Tonle Basak, Khan Chamkarmon, Phnom Penh, Cambodia.
ទូរស័ព្ទលេខ: (០២៣) ៧២៦ ១២៨/ ៧២៦ ១២៩ ទូរសារលេខ : (៨៥៥) ២៣-២១៧ ៣២០
Phone : (023) 726 128 / 726 129, Fax : (855) 23 - 217 320

## កំណត់សម្គាល់

I.ទម្រង់នៃការតាក់តែងលិខិតស្នាមរដ្ឋបាល បានរៀបចំចំនួន០៩ប្រភេទ ជាគំរូដូចខាងក្រោម៖

១.លិខិតទូលថ្វាយព្រះករុណាព្រះមហាក្សត្រ

២.លិខិតគោរពជូនសម្តេចនាយករដ្ឋមន្ត្រី

៣.លិខិតគោរពជូនឯកឧត្តមឧបនាយករដ្ឋមន្ត្រី

៤.លិខិតគោរពជូនឯកឧត្តមទេសរដ្ឋមន្ត្រី

៥.លិខិតគោរពជូនឯកឧត្តមរដ្ឋមន្ត្រី

៦.លិខិតជម្រាបជូនស្ថាប័នថ្នាក់ទាបជាងក្រសួង

៧.លិខិតជម្រាបជូនអង្គភាពក្រោមឱវាទ

៨.របាយការណ៍ផ្ញើជូនក្រសួង

៩.លិខិតអញ្ជើញផ្សេងៗ។

ឧទាហរណ៍៖

១.លិខិតទៅព្រះមហាក្សត្រ ប្រើពាក្យ សូមក្រាបបង្គំទូលថ្វាយ "**ព្រះករុណា ព្រះបាទសម្តេច**............." សរសេរ២ជួរ ខ្លឹមសារឃ្លាចុងក្រោយ សូម "**ព្រះករុណា ព្រះបាទសម្តេច**............. " ទ្រង់ព្រះមេត្តាទទួលនូវគារវភក្តីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុតអំពីទូលព្រះបង្គំ។

២.លិខិតទៅសម្តេច ប្រើពាក្យ សូមគោរពជូន "**សម្តេច**......................." សរសេរ២ជួរ ខ្លឹមសារឃ្លាចុងក្រោយ "សូម **សម្តេច**.................... មេត្តាទទួលនូវសេចក្តីគោរពដ៏ជ្រាលជ្រៅបំផុតអំពីខ្ញុំបាទ។"

៣. លិខិតទៅឯកឧត្តម ឬលោកជំទាវឧបនាយករដ្ឋមន្ត្រី ឬទេសរដ្ឋមន្ត្រី ប្រើពាក្យ **សូមគោរពជូន** ដូចគ្នា ឃ្លាចុងក្រោយ សូម ឯកឧត្តម ឬលោកជំទាវឧបនាយករដ្ឋមន្ត្រី ឬឯកឧត្តមទេសរដ្ឋមន្ត្រី មេត្តាទទួលនូវការគោរពដ៏ជ្រាលជ្រៅអំពីខ្ញុំ។

៤. លិខិតទៅឯកឧត្តម ឬលោកជំទាវរដ្ឋមន្ត្រីថ្នាក់ស្មើគ្នា ប្រើពាក្យ **គោរពជូន** ឃ្លាចុងក្រោយ សូម ឯកឧត្តម ឬលោកជំទាវរដ្ឋមន្ត្រី មេត្តាទទួលនូវការរាប់អានដ៏ស្មោះពីខ្ញុំ។

៥. លិខិតពីថ្នាក់ខ្ពស់ទៅថ្នាក់ទាបជាង ប្រើពាក្យ **ជម្រាបជូន** ឯកឧត្តម ឬលោក លោកស្រីប្រធាន ឃ្លាចុងក្រោយ សូម...........មេត្តាទទួលនូវការរាប់អានដ៏ស្មោះពីខ្ញុំ។

៦. ករណីមានការសម្រេចពីឯកឧត្តមរដ្ឋមន្ត្រីហើយៗ លិខិតជម្រាបអង្គភាពក្រោមឱវាទក្រសួង ប្រើពាក្យ ជម្រាបជូន...............ដោយយោងចំណារឯកឧត្តមរដ្ឋមន្ត្រី ចុះថ្ងៃទី...... ខែ....... ឆ្នាំ..... ឃ្លាចុងក្រោយ សូម........មេត្តាទទួលនូវការរាប់អានដ៏ស្មោះពីខ្ញុំ។ ការចុះហត្ថលេខា ត្រឹមអគ្គលេខាធិការដ្ឋាន។

៧.របាយការណ៍ថ្នាក់ដឹកនាំក្រសួង ឬប្រធានអង្គភាពដែលក្រសួងបានចាត់ឱ្យទៅចូលរួមកិច្ចប្រជុំ ពិធីផ្សេងៗ ឬចុះតាមមូលដ្ឋាន ស្នើរៀបចំដោយប្រើប្រាស់ក្បាលលិខិត (Logo) ក្រសួង ហើយឃ្លាចុងក្រោយ សូម **ឯកឧត្តមរដ្ឋមន្ត្រី** មេត្តាជ្រាប និងផ្តល់នូវអនុសាសន៍ណែនាំដោយក្តីអនុគ្រោះ។

៨.លិខិតអញ្ជើញ យើងប្រើពាក្យ **សូមគោរពអញ្ជើញ ឬ សូមអញ្ជើញ** ចុះបន្ទាត់គ្រែ **ឯកឧត្តម ឬ លោក**...................... ចុះបន្ទាត់ **ដើម្បីចូលរួម៖**.............. ចុះបន្ទាត់ **ទីកន្លែង៖**........... ចុះបន្ទាត់ **កាលបរិច្ឆេទ៖**..........ចុះបន្ទាត់ **ចុះហត្ថលេខាដោយអគ្គលេខាធិការតាមបញ្ជារដ្ឋមន្ត្រី**។ ករណីអញ្ជើញក្រៅក្រសួង ចុះហត្ថលេខាដោយ **ឯកឧត្តមរដ្ឋមន្ត្រី**។

II.ការកំណត់រឹម(គែម)នៅក្នុងលិខិត (Page Setup Margins) ដូចខាងក្រោម៖

-ខាងឆ្វេង (Left) ទុក ២.៥សម

-ខាងស្តាំ (Right) ទុក ១.៥សម

-ខាងលើ (Top) ទុក ១សម

-ខាងក្រោម (Bottom) ទុក ១.៥សម

III. ចំពោះប្រភេទក្រដាស គឺប្រភេទ A4 (Page Setup ➡ Paper ➡ Paper Size យក A4) និងមានក្បាលលិខិត (Logo) ជាគំរូភ្ជាប់មកជាមួយ។

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

លេខ ៤៩១ កសក

រាជធានីភ្នំពេញ, ថ្ងៃទី.១៧...ខែ.ឧសភា.ឆ្នាំ ២០១៧

## ជម្រាបជូន

-ឯកឧត្តម លោក លោកស្រីប្រធានអង្គភាពក្រោមឱវាទក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

-លោកប្រធានមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានី-ខេត្ត

**កម្មវត្ថុ** ៖ការរៀបចំលិខិតតាមទម្រង់ណែនាំរបស់ក្រសួងឱ្យបានឯកភាពគ្នា។

**ជូនភ្ជាប់** ៖គំរូលិខិតចំនួន.................................................................................................០៩ច្បាប់។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុនិងជូនភ្ជាប់ខាងលើ ខ្ញុំសូមជម្រាប ឯកឧត្តម លោក លោកស្រីប្រធានគ្រប់អង្គភាពក្រោមឱវាទក្រសួងជ្រាបថា ដើម្បីចៀសវាងនូវការប្រើពាក្យ ទម្រង់លិខិតស្នាម ទំហំ និងហ្វុងអក្សររដ្ឋបាលខុសៗគ្នាតាមអង្គភាពនីមួយៗ និងដើម្បីឱ្យមានការឯកភាពលើទម្រង់លិខិតរដ្ឋបាលរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ខ្ញុំសូមឯកឧត្តម លោក លោកស្រីប្រធានអង្គភាពចាត់ចែងឱ្យការិយាល័យរដ្ឋបាល នៃអង្គភាពនីមួយៗរៀបចំលិខិតតាមទម្រង់ណែនាំរបស់ក្រសួងដូចមានជូនភ្ជាប់មកជាមួយចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូម ឯកឧត្តម លោក លោកស្រីប្រធានអង្គភាពជ្រាប និងអនុវត្តតាមខ្លឹមសារខាងលើឱ្យបានសមស្របតាមការគួរ។

រដ្ឋមន្ត្រី

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

យុន្ធ ភ្ញូថង

**ចម្លងជូន៖**

-ថ្នាក់ដឹកនាំក្រសួង

-ខុទ្ទកាល័យរដ្ឋមន្ត្រី

"ដើម្បីជ្រាប"

-ឯកសារ កាលប្បវត្តិ

អាស័យដ្ឋានលេខ ២០០ មហាវិថីព្រះនរោត្តម សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ កម្ពុជា
№ 200 Preah Norodom Blvd., Sangkat Tonle Basak, Khan Chamkarmon, Phnom Penh, Cambodia
ទូរស័ព្ទលេខ :(០២៣) ៧២៦ ១២៨ / ៧២៦ ១២៩ ទូរសារលេខ : (៨៥៥) ២៣-២១៧ ៣២០
Phone : (023) 726 128 / 726 129, Fax : (855) 23 - 217 320

"13 Khmer OS Muol Ligh
Paragraph Center

# **សារលិខិតថ្វាយព្រះពរ**

"11 Khmer OS
Muol Ligh
Paragraph Center

**ព្រះករុណា ព្រះបាទសម្តេច ព្រះបរមនាថ នរោត្តម សីហមុនី ព្រះមហាក្សត្រ**
**នៃព្រះរាជាណាចក្រកម្ពុជា ក្នុងព្រះរាជពិធីបុណ្យខួបលើកទី ១១**
**នៃការឡើងគ្រងព្រះបរមរាជសម្បត្តិ**

**សូមក្រាបបង្គំទូលថ្វាយព្រះករុណាជាអម្ចាស់ជីវិតលើត្បូង ជាទីសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត !**

2 cm ←--------→ | ←---- 1.5cm

ទូលព្រះបង្គំ យើងខ្ញុំទាំងអស់គ្នាជាថ្នាក់ដឹកនាំ មន្ត្រីរាជការគ្រប់ជាន់ថ្នាក់នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ សូមព្រះបរមរាជានុញ្ញាតសម្តែងនូវកត្តញ្ញូតាធម៌ និងមនោសញ្ចេតនារំភើបរីករាយឥតឧបមា ដើម្បីចូលរួមអបអរសាទរព្រះរាជពិធីបុណ្យ ខួបលើកទី ១១ ដែលជាទិវាប្រវត្តិសាស្ត្រនៃការឡើងគ្រងព្រះបរមរាជសម្បត្តិរបស់ **ព្រះករុណាជាអម្ចាស់ជីវិតតម្កល់លើត្បូង** ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត នាថ្ងៃសៅរ៍ ទី២៩ ខែតុលា ឆ្នាំ២០១៥។

ក្នុងឱកាសដ៏វិសេសវិសាលនេះ ទូលព្រះបង្គំយើងខ្ញុំទាំងអស់គ្នា សូមលើកហត្ថអញ្ជលីបួងសួងដល់គុណបុណ្យព្រះរតនត្រ័យ កែវទាំងបី និងវត្ថុស័ក្តិសិទ្ធិក្នុងលោកទាំងអស់ មានទេវតារក្សាព្រះមហាស្វេតច្ឆត្រ រាជបល្ល័ង្ក និងព្រះវិញ្ញាណក្ខន្ធនៃអតីតព្រះមហាក្សត្រ ព្រះមហាក្សត្រិយានី ដួងវិញ្ញាណក្ខន្ធ ព្រះករុណា "**ព្រះបរមរតនកោដ្ឋ**" សូមទ្រង់តាមជួយប្រោះព្រំបីបាច់ថែរក្សា **ព្រះករុណា ព្រះបាទសម្តេច ព្រះបរមនាថ នរោត្តម សីហមុនី ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា** និងសូមទូលថ្វាយព្រះរាជកុសល ព្រះស័ព្ទសាធុការពរបវរមហាប្រសើរចំពោះ **ព្រះករុណាជាអម្ចាស់ជីវិតលើត្បូង** ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត សូម **ព្រះអង្គ** ទ្រង់ប្រកបដោយព្រះបញ្ញាញាណវាងវៃ ព្រះកាយពលមាំមួន ព្រះជន្មាយុយឺនយូរជាងរយព្រះវស្សា ដើម្បីទ្រង់គង់ប្រថាប់ក្នុងព្រះបរមសិរីរាជសម្បត្តិយូរអង្វែង ជាមហាម្លប់ដ៏សុខក្សេមក្សាន្ត ត្រជាក់ត្រជុំរបស់មាតុភូមិអង្គរដ៏បវរ និងប្រជារាស្ត្រខ្មែររបស់ **ព្រះអង្គ** ជានិច្ចនិរន្តរ៍តរៀងទៅ។

សូម **ព្រះករុណា** ជាអម្ចាស់ជីវិតតម្កល់លើត្បូង ទ្រង់ព្រះមេត្តាទទួលនូវគារវភក្តីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុតពីទូលព្រះបង្គំទាំងអស់គ្នា។

សេចក្តីគួរពុំគួរ សូម **ព្រះករុណា** ជាអម្ចាស់ជីវិតតម្កល់លើត្បូង ទ្រង់ព្រះមេត្តាប្រោសប្រណីដោយក្តីអនុគ្រោះ។

ក្រាបបង្គំទូលថ្វាយនៅរាជធានីភ្នំពេញ , ថ្ងៃទី ខែតុលា ឆ្នាំ២០១៥

"11 Khmer OS
Muol Ligh

**រដ្ឋមន្ត្រី**
**ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**

"11 Khmer OS Muol Light

**សូមគោរពជូន**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា**

"12 KhmerOS Muol Light

"11 KhmerOS Muol Light

**កម្មវត្ថុ ៖** សំណើសុំគោរពអញ្ជើញ **សម្តេច** និង **សម្តេចកិត្តិព្រឹទ្ធបណ្ឌិត** ចូលរួមជាអធិបតីដ៏ខ្ពង់ខ្ពស់ក្នុងពិធីប្រគល់សញ្ញាបត្រដល់និស្សិតនៃសាកលវិទ្យាល័យភូមិន្ទកសិកម្មចំនួន១.៦៣៩នាក់។

**ជូនភ្ជាប់៖** -កម្មវិធីប្រគល់សញ្ញាបត្រចំនួន.......................................................................០១ច្បាប់

-បញ្ជីរាយនាមនិស្សិតត្រូវទទួលសញ្ញាបត្រចំនួន...............................................០១ច្បាប់។

2.5cm

1.5cm

សេចក្តីដូចមានចែងក្នុងកម្មវត្ថុនិងជូនភ្ជាប់ខាងលើ ខ្ញុំបាទសូមជម្រាបជូន **សម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី** ជាទីគោរពដ៏ខ្ពង់ខ្ពស់ មេត្តាជ្រាបថា និស្សិតនៃសាកលវិទ្យាល័យភូមិន្ទកសិកម្មចំនួន ១ ៦៣៩នាក់ បានឡើងការពារនិក្ខេបបទសារណា និងរបាយការណ៍បញ្ចប់ការសិក្សារបស់ខ្លួនប្រកបដោយជោគជ័យកាលពីឆ្នាំ២០១៣ ២០១៤ ២០១៥ និងឆ្នាំ២០១៦ ហើយគ្រោងនឹងរៀបចំពិធីប្រគល់សញ្ញាបត្រនាពេលខាងមុខ។

ដើម្បីញ៉ាំងឲ្យពិធីនេះប្រព្រឹត្តទៅប្រកបដោយភាពឱឡារិក ព្រមទាំងទទួលបាននូវមតិណែនាំ និងអនុសាសន៍ល្អៗសម្រាប់អនុវត្តនាពេលអនាគតនោះ ខ្ញុំបាទសូមគោរពអញ្ជើញ **សម្តេចតេជោ** និង **សម្តេចកិត្តិព្រឹទ្ធបណ្ឌិត** មេត្តាពិនិត្យលទ្ធភាពពេលវេលាដ៏សមស្រប ដើម្បីឆ្លៀតឱកាសដ៏មមាញឹកនិងមានតម្លៃ អញ្ជើញចូលរួមជាអធិបតីដ៏ខ្ពង់ខ្ពស់ ក្នុងពិធីប្រគល់សញ្ញាបត្រដល់និស្សិតនៃសាកលវិទ្យាល័យភូមិន្ទកសិកម្ម ចំនួន១ ៦៣៩នាក់ ដែលគ្រោងរៀបចំនៅសាកលវិទ្យាល័យភូមិន្ទកសិកម្ម តាមកម្មវិធីដូចបានគោរពជម្រាបជូនភ្ជាប់ដោយក្តីអនុគ្រោះ។

សូម **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** មេត្តាទទួលនូវសេចក្តីគោរពដ៏ជ្រាលជ្រៅបំផុតអំពីខ្ញុំបាទ។

ស្មើគ្នាទាំងសងខាង

**រដ្ឋមន្ត្រី**

**ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**

"11 Khmer OS Muol Light

**ចម្លងជូន៖** "9 Khmer OS Muol Light

-គ្រប់អង្គភាពក្រោមឱវាទ

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

" ដើម្បីជាព័ត៌មាន "

-ឯកសារ កាលប្បវត្តិ

"9 Khmer OS Battambang

"11 Khmer OS Muol Ligh Paragraph Center

"11 Khmer OS Battambang

**សូមគោរពជូន**

**ឯកឧត្តម សុខ អាន ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**

1.5cm

"11 Khmer OS Muol Light

**កម្មវត្ថុ** ៖ សំណើសូមអញ្ជើញចូលរួមជាគណៈអធិបតី ក្នុងពិធីប្រគល់សញ្ញាបត្រដល់និស្សិត ចំនួន ១ ៦៣៩ នាក់ នៅវិទ្យាស្ថានជាតិអប់រំ ។

**ជូនភ្ជាប់** ៖ កម្មវិធីប្រគល់សញ្ញាបត្រ ........................................................................ចំនួន ០១ច្បាប់ ។

2.5cm

សេចក្តីដូចមានចែងក្នុងកម្មវត្ថុ និងជូនភ្ជាប់ខាងលើ ខ្ញុំសូមជម្រាបជូន ឯកឧត្តមឧបនាយករដ្ឋមន្ត្រី មេត្តាជ្រាបថា សាកលវិទ្យាល័យភូមិន្ទកសិកម្មនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ នឹងរៀបចំពិធីប្រគល់សញ្ញាបត្រដល់និស្សិតថ្នាក់បរិញ្ញាបត្ររង បរិញ្ញាបត្រ បរិញ្ញាបត្រជាន់ខ្ពស់ និងថ្នាក់បណ្ឌិត ចំនួន ១ ៦៣៩ នាក់ ដែលនឹងប្រព្រឹត្តទៅនៅថ្ងៃទី..... ខែ..... ឆ្នាំ........... វេលាម៉ោង០៨ម០០នាទីព្រឹក ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** ។ ពិធីប្រគល់សញ្ញាបត្រនេះនឹងប្រារព្ធធ្វើនៅសាលប្រជុំ សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នៃវិទ្យាស្ថានជាតិអប់រំ (ក្បែរវិមានឯករាជ្យ) ។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូម ឯកឧត្តមឧបនាយករដ្ឋមន្ត្រី មេត្តាអញ្ជើញចូលរួមជាគណៈអធិបតីក្នុងពិធីប្រគល់សញ្ញាបត្រតាមកាលបរិច្ឆេទនិងទីកន្លែងខាងលើ ដោយអនុគ្រោះ ។

សូម ឯកឧត្តមឧបនាយករដ្ឋមន្ត្រី មេត្តាទទួលនូវការគោរពដ៏ជ្រាលជ្រៅអំពីខ្ញុំ ។

ស្មើគ្នាទាំងសង់ខាង

**រដ្ឋមន្ត្រី**

**ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**

"11 Khmer OS Muol Light

* សូមមេត្តាឆ្លើយតបពីការចូលរួម
ឬទំនាក់ទំនងព័ត៌មានបន្ថែមតាម
ទូរស័ព្ទលេខ៖ ០១២ ៣៣៤ ៧១៥
០១៦ ៣១៤ ៩៨៤

"9 Khmer OS Battambang

"11 Khmer OS MuolLigh Paragraph Center

"11 Khmer OS Battambang

**សូមគោរពជូន**

**ឯកឧត្តម នាយ ថន ទេសរដ្ឋមន្ត្រីរដ្ឋមន្ត្រីក្រសួងផែនការ**

1.5cm

**កម្មវត្ថុ** ៖ សំណើសូមអញ្ជើញចូលរួមជាគណៈអធិបតី ក្នុងពិធីប្រគល់សញ្ញាបត្រដល់និស្សិតចំនួន១៦៣៩ នាក់ នៅវិទ្យាស្ថានជាតិអប់រំ ។

**ជូនភ្ជាប់** ៖ កម្មវិធីប្រគល់សញ្ញាបត្រ ...........................................................................ចំនួន ០១ច្បាប់ ។

2.5cm

សេចក្តីដូចមានចែងក្នុងកម្មវត្ថុ និងជូនភ្ជាប់ខាងលើ ខ្ញុំសូមជម្រាបជូន ឯកឧត្តមទេរដ្ឋមន្ត្រី មេត្តាជ្រាបថា សាកលវិទ្យាល័យភូមិន្ទកសិកម្មនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ នឹងរៀបចំពិធីប្រគល់សញ្ញាបត្រដល់និស្សិតថ្នាក់បរិញ្ញាបត្ររង បរិញ្ញាបត្រ បរិញ្ញាបត្រជាន់ខ្ពស់ និងថ្នាក់បណ្ឌិត ចំនួន ១ ៦៣៩ នាក់ ដែលនឹងប្រព្រឹត្តទៅនៅថ្ងៃទី.....ខែ........ឆ្នាំ............ វេលាម៉ោង០៨ម០០នាទីព្រឹក ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា**។ ពិធីប្រគល់សញ្ញាបត្រនេះនឹងប្រារព្ធធ្វើនៅសាលប្រជុំ សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នៃវិទ្យាស្ថានជាតិអប់រំ (ក្បែរវិមានឯករាជ្យ) ។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូម ឯកឧត្តមទេសរដ្ឋមន្ត្រី មេត្តាអញ្ជើញចូលរួមជាគណៈអធិបតីក្នុងពិធីប្រគល់សញ្ញាបត្រតាមកាលបរិច្ឆេទនិងទីកន្លែងខាងលើ ដោយអនុគ្រោះ ។

សូម ឯកឧត្តមទេសរដ្ឋមន្ត្រី មេត្តាទទួលនូវការគោរពដ៏ជ្រាលជ្រៅអំពីខ្ញុំ ។

ស្មើគ្នាទាំងសង់ខាង

**រដ្ឋមន្ត្រី**

**ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**

"11Khmer OS Muol Light

* សូមមេត្តាឆ្លើយតបពីការចូលរួម
ឬទំនាក់ទំនងព័ត៌មានបន្ថែមតាម
ទូរស័ព្ទលេខ៖ ០១២ ៣៣៤ ៧១៥
០១៦ ៣១៤ ៩៨៤

"9 Khmer OS Battambang

"11 Khmer OS Battambang

"11 Khmer OS MuolLigh
Paragraph Center

**គោរពជូន**

**ឯកឧត្តមរដ្ឋមន្ត្រីក្រសួងយុត្តិធម៌**

2.5cm

1.5c

**កម្មវត្ថុ** ៖ សំណើសូមអញ្ជើញចូលរួមជាគណៈអធិបតី ក្នុងពិធីប្រគល់សញ្ញាបត្រដល់និស្សិតចំនួន១ ៦៣៩ នាក់ នៅវិទ្យាស្ថានជាតិអប់រំ ។

**ជូនភ្ជាប់** ៖ កម្មវិធីប្រគល់សញ្ញាបត្រ ............................................................................ចំនួន ០១ច្បាប់ ។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុ និងជូនភ្ជាប់ខាងលើ ខ្ញុំសូមជម្រាបជូន ឯកឧត្តរដ្ឋមន្ត្រី មេត្តាជ្រាបថា សាកលវិទ្យាល័យភូមិន្ទកសិកម្មនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ នឹងរៀបចំពិធីប្រគល់សញ្ញាបត្រ ដល់និស្សិតថ្នាក់បរិញ្ញាបត្ររង បរិញ្ញាបត្រ បរិញ្ញាបត្រជាន់ខ្ពស់ និងថ្នាក់បណ្ឌិត ចំនួន ១ ៦៣៩ នាក់ ដែលនឹងប្រព្រឹត្តទៅនៅថ្ងៃទី... ខែ..... ឆ្នាំ......... វេលាម៉ោង០៨ម០០នាទីព្រឹក ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** ។ ពិធីប្រគល់សញ្ញាបត្រនេះនឹងប្រារព្ធធ្វើនៅសាលប្រជុំ សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នៃវិទ្យាស្ថានជាតិអប់រំ (ក្បែរវិមានឯករាជ្យ) ។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូម ឯកឧត្តមរដ្ឋមន្ត្រី មេត្តាអញ្ជើញចូលរួមជាគណៈអធិបតី ក្នុងពិធីប្រគល់សញ្ញាបត្រតាមកាលបរិច្ឆេទនិងទីកន្លែងខាងលើ តាមការគួរ ។

សូម ឯកឧត្តមរដ្ឋមន្ត្រី មេត្តាទទួលនូវការរាប់អានដ៏ស្មោះពីខ្ញុំ ។

ស្មើគ្នាទាំងសងខាង

**រដ្ឋមន្ត្រី**

**ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**

"11 Khmer OS Muol Light

* សូមមេត្តាឆ្លើយតបពីការចូលរួម
ឬទំនាក់ទំនងព័ត៌មានបន្ថែមតាម
ទូរស័ព្ទលេខ៖ ០១២ ៣៣៤ ៧១៥
០១៦ ៣១៤ ៩៨៤

"9 Khmer OS Battambang

"11 Khmer OS Muol Ligh Paragraph Center

"11 Khmer OS Battambang

**ជម្រាបជូន**

**ឯកឧត្តមប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកមជ្ឈមណ្ឌលសកម្មភាពកម្ចាត់មីនកម្ពុជា**

"11 Khmer OS Muol Light

**កម្មវត្ថុ** ៖ សំណើសុំអនុញ្ញាតចាត់មន្ត្រីជំនាញចុះពិនិត្យគ្រាប់យុទ្ធភ័ណ្ឌមិនទាន់ផ្ទុះ ស្ថិតនៅភូមិថ្មសំលៀ ឃុំក្រយា ស្រុកសន្ទុក ខេត្តកំពង់ធំ។

**យោង** ៖ ច្បាប់ស្តីពីព្រៃឈើ។

2.5cm

1.5cm

សេចក្តីដូចមានចែងក្នុងកម្មវត្ថុនិងយោងខាងលើ ខ្ញុំសូមជម្រាបជូន ឯកឧត្តមប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកមជ្ឈមណ្ឌលសកម្មភាពកម្ចាត់មីនកម្ពុជាជ្រាបថា អនុលោមតាមមាត្រា៣០ នៃច្បាប់ស្តីពីព្រៃឈើ បានចែងពីការរៀបចំបុណ្យរុក្ខទិវា។ សម្រាប់ឆ្នាំនេះ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានសម្រេចរៀបចំពិធីបុណ្យរុក្ខទិវា នាថ្ងៃទី...... ខែ........ ឆ្នាំ......... ដែលមានទីតាំងស្ថិតនៅភូមិថ្មសំលៀង ឃុំក្រយា ស្រុកសន្ទុក ខេត្តកំពង់ធំ ក្រោមព្រះរាជាធិបតីភាពដ៏ខ្ពង់ខ្ពស់បំផុតរបស់ **ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា។**

ដើម្បីឱ្យទីតាំងប្រារព្ធពិធីនេះប្រព្រឹត្តទៅប្រកបដោយសុវត្ថិភាពនោះ ខ្ញុំសូមឯកឧត្តមប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកមជ្ឈមណ្ឌលសកម្មភាពកម្ចាត់កម្ពុជា មេត្តាចាត់មន្ត្រីជំនាញចុះពិនិត្យគ្រាប់យុទ្ធភ័ណ្ឌមិនទាន់ផ្ទុះនៅទីតាំងប្រារព្ធពិធីបុណ្យខាងលើតាមការគួរ។

សូម ឯកឧត្តមប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកមជ្ឈមណ្ឌលសកម្មភាពកម្ចាត់មីនកម្ពុជា ទទួលនូវការរាប់អានដ៏ស្មោះពីខ្ញុំ។

ស្មើគ្នាទាំងសងខាង

**រដ្ឋមន្ត្រី**

**ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**

"11 Khmer OS Muol Light

**ចម្លងជូន:**

"9 Khmer OS Muol Light

- -ទីស្តីការគណៈរដ្ឋមន្ត្រី
- -ក្រសួងមហាផ្ទៃ
- -ក្រសួងការពារជាតិ
- -ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- -សាលាខេត្តកំពង់ធំ "ដើម្បីជូនជ្រាប"
- -រដ្ឋបាលព្រៃឈើ "ដើម្បីមុខការ"
- -ឯកសារ កាលប្បវត្តិ

"9 Khmer OS Battambang

"11 Khmer OS MuolLigh
Paragraph Center

**ជម្រាបជូន**

**លោកប្រធាននាយកដ្ឋានផលិតកម្មនិងបសុពេទ្យាបាល**

"11 Khmer OS Battambang

"11 Khmer OS Muol Light

**កម្មវត្ថុ** ៖ករណីរបាយការណ៍ស្តីពីការចាប់ឃាត់រថយន្ត០២គ្រឿងដឹកទាកាតីកាំបែលរស់ចំនួន៤៥០០ក្បាល។

**យោង** ៖-លិខិតលេខ១១៧០ ផប ចុះថ្ងៃទី........ ខែ.......... ឆ្នាំ............. របស់នាយកដ្ឋានផលិតកម្មនិងបសុព្យាបាល

-ចំណារឯកឧត្តមរដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ចុះថ្ងៃទី......... ខែ............. ឆ្នាំ...................។

1.5cm

2.5cm

តបតាមកម្មវត្ថុនិងយោងខាងលើ ខ្ញុំសូមជម្រាបលោកប្រធានជ្រាបថា ចំពោះករណីរថយន្តដឹកទាកាតីកំបែលរស់ចំនួន៤៥០០ក្បាល គ្មានលិខិតអនុញ្ញាតត្រឹមត្រូវបង្កឡើងដោយឈ្មោះ យង់ ធឿនភេទប្រុសដែលត្រូវបានក្រុមអន្តរាគមន៍បង្ក្រាបបទល្មើសអាជីវកម្មចលនាសត្វ និងផលិតផលមានដើមកំណើតពីសត្វនៃនាយកដ្ឋានផលិតកម្មនិងបសុព្យាបាល ធ្វើការចាប់ឃាត់នៅទល់មុខក្លោងទ្វារវត្តចាស់ លើផ្លូវជាតិលេខ៦អា ក្នុងឃុំព្រែកដំបង ស្រុកមុខកំពូល ខេត្តកណ្តាលនោះ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានសម្រេចឲ្យធ្វើការផាកពិន័យតាមមាត្រា៣០ នៃអនុក្រឹត្យលេខ១៦ អនក្រ.បក ចុះថ្ងៃទី១៣ ខែមីនា ឆ្នាំ២០០៣ ស្តីពីការត្រួតពិនិត្យអនាម័យសត្វ និងផលិតផលមានដើមកំណើតពីសត្វដែលនាំឱ្យប៉ះពាល់ដល់សុខភាពសត្វ និងសុខភាពសាធារណៈ។ ករណីវិភាគរកឃើញថាមានមេរោគ ឬខូចគុណភាព ត្រូវចាត់វិធានការកំទេចចោល។

អាស្រ័យហេតុនេះ សូម លោកប្រធាន ជ្រាបនិងចាត់ចែងអនុវត្តតាមខ្លឹមសារខាងលើឲ្យបានសមស្របតាមការគួរ។

ស្មើគ្នាទាំងសងខាង

**អគ្គលេខាធិការ**

**ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**

"11 Khmer OS Muol Light

**ចម្លងជូន៖** "9 Khmer OS Muol Light

- អគ្គាធិការដ្ឋាន
- នាយកដ្ឋានគណនេយ្យ ហិរញ្ញវត្ថុ
- មន្ទីរកសិកម្មខេត្តកណ្តាល
  "ដើម្បីជូនជ្រាប"
- ឯកសារ កាលប្បវត្តិ

"9 Khmer OS Battambang

2.5cm

"12 Khmer OS Muol Light → **លិខិតអញ្ជើញ**

"20 Tacteing (3)

"11 Khmer OS Muol Light

**រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**
**សូមអញ្ជើញ**

"11 Khmer OS Battambang

- ឯកឧត្តម គង់ចាន់ អនុរដ្ឋលេខាធិការក្រសួងកសិកម្មរុក្ខាប្រមាញ់និងនេសាទ
- ឯកឧត្តម ឆេង គឹមស៊ុន ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកប្រធានរដ្ឋបាលព្រៃឈើ
- ឯកឧត្តម ង៉ោ ប៊ុនថាន សាកលវិទ្យាធិការនៃសាកលវិទ្យាល័យភូមិន្ទកសិកម្ម
- លោក ប្រាក់ ថាវអមិដា អគ្គលេខាធិការរងនៃក្រសួងកសិកម្មរុក្ខាប្រមាញ់និងនេសាទ
- លោក សៀ រ៉ា អនុប្រធានរដ្ឋបាលព្រៃឈើ
- លោក ប៉ែន វុធ អគ្គនាយករងនៃអគ្គនាយកដ្ឋានកសិកម្ម
- លោក ស្រ៊ិន សុខុម អគ្គនាយករងនៃអគ្គនាយកដ្ឋានកសិកម្ម
- កញ្ញា ចាន់ ផលលឿន អគ្គនាយិការរងនៃអគ្គនាយកដ្ឋានកសិកម្ម
- លោក ជា ច័ន្ទវាសនា ប្រធាននាយកដ្ឋានកិច្ចការរដ្ឋបាល
- លោក គង់ ភាជ ប្រធាននាយកដ្ឋានកសិ-ឧស្សាហកម្ម

"11 Khmer OS Muol Light

**មកចូលរួមប្រជុំ** ៖រៀបចំសន្និបាតកសិករលើកទី៧ ឆ្នាំ២០១៦ ក្រោមអធិបតីភាព **ឯកឧត្តម ឌី សុគន្ធ** រដ្ឋលេខាធិការ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

**ទីកន្លែង** ៖នៅទីស្តីការក្រសួងកសិកម្មរុក្ខាប្រមាញ់និងនេសាទ (សាលប្រជុំធំន. គណនេយ្យហិរញ្ញវត្ថុ)

**កាលបរិច្ឆេទ** ៖ថ្ងៃទី.......ខែ..........ឆ្នាំ..........វេលាម៉ោង.................។

"11 Khmer OS Muol Light

**ត.ប.រដ្ឋមន្ត្រី**
**ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**
**អគ្គលេខាធិការ**

**ចម្លងជូន៖** → "9 Khmer OS Muol Light

"9 Khmer OS Battambang

-ខុទ្ទកាល័យរដ្ឋមន្ត្រី
"ដើម្បីជូនជ្រាប"
-នាយកដ្ឋានគណនេយ្យហិរញ្ញវត្ថុ
-នាយកដ្ឋានកិច្ចការរដ្ឋបាល
"ដើម្បីមុខការ"
-ឯកសារ កាលប្បវត្តិ

"11Khmer OS Muol Ligh
Paragraph Center

**សូមគោរពជូន**

**ឯកឧត្តមរដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**

"11 Khmer OS Battambang

**កម្មវត្ថុ** ៖របាយការណ៍ស្ដីពី..................................................................................................

..................................................................................................។

"11 Khmer OS Muol Ligh

1.5cm

**យោង** ៖-ចំណារឯកឧត្តមរដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ចុះថ្ងៃទី.........ខែ.............ឆ្នាំ..............
ឬលិខិតបញ្ជាបេសកកម្មលេខ..................................................................................

2.5cm

សេចក្តីដូចមានចែងក្នុងកម្មវត្ថុនិងយោងខាងលើ ខ្ញុំបាទសូមអនុញ្ញាតជម្រាបជូន **ឯកឧត្តមរដ្ឋមន្ត្រី** មេត្តាជ្រាបថា..................................................................................................................

..................................................................................................................

..................................................................................................................

..................................................................................................................

..................................................................................................................

..................................................................................................................

.................................................................................................................។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូម **ឯកឧត្តមរដ្ឋមន្ត្រី** មេត្តាជ្រាប និងផ្តល់នូវអនុសាសន៍ណែនាំដោយក្តីអនុគ្រោះ។

សូម **ឯកឧត្តមរដ្ឋមន្ត្រី** មេត្តាទទួលនូវការគោរពដ៏ជ្រាលជ្រៅអំពីខ្ញុំ។

រាជធានីភ្នំពេញ, ថ្ងៃទី ខែ ឆ្នាំ២០១៦

*កំណត់សម្គាល់៖ ករណីលិខិតរដ្ឋបាលផ្សេងៗដែលស្នើសុំមកក្រសួង ក៏រៀបចំតាមទម្រង់នេះដែរ។

### ៦/ ដីកាអម ឬដីកាបញ្ជូនត្រូវឆ្លើយតប

### ៦.១.ដីកាអម ឬដីកាបញ្ជូន

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**សាលាទ័ណ្ឌចំការមន**

លេខ............

## ដីកាអម

បានបញ្ជូនមក : ..........................................................................................

| ល.រ | រាយមុខលិខិត | ចំនួន | ផ្សេងៗ |
|---|---|---|---|
| ១ | កំណត់ហេតុអង្គប្រជុំ | ១ ច្បាប់ | "ដើម្បីជ្រាបជាពតិមាន" |
| ២ | របាយការណ៍ប្រចាំសប្តាហ៍ | ១ ច្បាប់ | "ដើម្បីជ្រាបជារបាយការណ៍" |
| ៣ | ព្រឹត្តិប័ត្រប្រចាំខែ | ១០ ច្បាប់ | "ដើម្បីអាន" |

ភ្នំពេញ, ថ្ងៃទី .......ខែ...........ឆ្នាំ១៩៩...

**អភិបាលខ័ណ្ឌ**

ហត្ថលេខា, ឈ្មោះ និង ត្រា

គេប្រើដីកាអមសំរាប់បញ្ជូនសំណុំលិខិតណា ដែលគ្មានប្រភព, លេខ និង របស់ផ្សេងៗទោះតិចក្តីច្រើនក្តី ដោយអនុលោមទៅតាមចំនួន ឬ ទំហំរបស់នោះផង ។ បើគ្មានដីកាអមទេ លិខិតដែលគ្មានប្រភព និងលេខ គេមិនសន្មត់បានថា លិខិតនោះចេញពីកន្លែងណាទេ ។ ហេតុនេះហើយបានជាគេប្រើដីកាអមសម្រាប់កត់សំគាល់ប្រភព និង លេខក្នុងការបញ្ជូនលិខិតដែលគ្មានប្រភព ហើយដីកាអមគេធ្វើជាពីរច្បាប់ ។

គ្រប់ដីកាអមទាំងអស់ គេត្រូវធ្វើភ្ជាប់ជាមួយនឹងឯកសារណា ឬ សំភារៈណាដែលបានចុះក្នុងចំណុចរាយមុខលិខិត ។ គេមិនត្រូវបញ្ជូនដីកាអមតែមួយសន្លឹកដោយគ្មានភ្ជាប់ឯកសារឬសំភារៈទៅជាមួយនោះទេ។

អ្នកទទួលដីការួចហើយ ត្រូវរាប់មុខលិខិត ឬរបស់ផ្សេងៗដែលមាននៅក្នុងដីកាអម ឃើញថាគ្រប់ចំនួនហើយ ត្រូវសរសេរចារបញ្ជាក់ថា គ្រប់ចំនួន ដោយចុះ ថ្ងៃ ខែ ឆ្នាំ ហត្ថលេខា និង ឈ្មោះបញ្ជូនមួយច្បាប់ត្រឡប់មកម្ចាស់ដើមមួយច្បាប់វិញ ។